ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ១០១ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ

* * * * *

## ឧបនាយករដ្ឋមន្ត្រី
## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០២/០១១ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យសហគ្រាស សវនកម្មគណនេយ្យសហគ្រាស និងវិជ្ជាជីវៈគណនេយ្យ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០០៣ ស្តីពីការបង្កើតនាយកដ្ឋានហិរញ្ញវត្ថុមូលដ្ឋាន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ២០០៤ និង អនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០០៨ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួននៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរសព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

Downloaded from http://www.khmerlaws.com

- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតម្លើងទីចាត់ការគយនិងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិ ឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ០៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសមាសភាព និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាជាតិគណនេយ្យ
- បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
- បានឃើញប្រកាសលេខ ០៦៨ សហវ/ប្រកចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក)
- បានឃើញសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម
- តាមសំណើរបស់ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ

## ស ម្រេ ច

**ប្រការ ១.-**

ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវអនុវត្តតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក) និងនិងសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**ប្រការ ២.-**

ក្នុងរយៈពេលអន្តរកាល ដោយគិតចាប់ពីកាលបរិច្ឆេទចូលជាធរមាននៃប្រកាសនេះ រហូតដល់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១១ ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ ត្រូវអនុវត្តតាមស្តង់ដារគណនេយ្យ និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ ដូចមានកំណត់ក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។ ក្រុមហ៊ុន បោះផ្សាយលក់មូលបត្រជាសាធារណៈ អាចប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ



Downloaded from http://www.khmerlaws.com

អន្តរជាតិនៃកម្ពុជា ដូចមានកំណត់ក្នុងប្រកាសលេខ ០៦៨ សហវ/ប្រក របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ចុះថ្ងៃទី ០៨ ខែ មករា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុកម្ពុជា (ស.រ.ហ.ក) និងសេចក្តីជូនដំណឹងលេខ ០៩៧/០៩ សហវ/ក.ជ.គចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៩ ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម។

**ប្រការ ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៤.-**

អគ្គលេខាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក ប្រធានក្រុមប្រឹក្សាជាតិគណនេយ្យ អគ្គនាយកនៃគណៈកម្មការមូលបត្រកម្ពុជា នាយកខុទ្ទកាល័យ ប្រធានវិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ និងបុគ្គលពាក់ព័ន្ធ ត្រូវអនុវត្តតាមខ្លឹមសារនៃប្រកាសនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ[illegible] ឆ្នាំ២០១១

គាត ឈន់

**កន្លែងទទួល ÷**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
-ខុទ្ទកាល័យឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
-ធនាគារជាតិនៃកម្ពុជា
-គណៈកម្មការមូលបត្រកម្ពុជា
-ក្រុមប្រឹក្សាជាតិគណនេយ្យ
-វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា
-គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
"ដើម្បីជូនជ្រាប"
-ដូចប្រការ ៤
"ដើម្បីអនុវត្ត"
-រាជកិច្ច និងសេវាកុំព្យូទ័រ
-ឯកសារ-កាលប្បវត្តិ



Downloaded from http://www.khmerlaws.com

**ឧបសម្ព័ន្ធនៃប្រកាសលេខ....**

**ស្តីពីការដាក់ឱ្យប្រើស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ សម្រាប់ក្រុមហ៊ុនបោះផ្សាយលក់មូលបត្រជាសាធារណៈ**

**ចុះថ្ងៃទី ខែ ឆ្នាំ ២០១១**

*****

ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុ

១- ស.រ.ហ.អ.ក ៤ : កិច្ចសន្យាធានារ៉ាប់រង

២- ស.រ.ហ.អ.ក ៧ : ឧបករណ៍ហិរញ្ញវត្ថុៈការលាតត្រដាងព័ត៌មាន

៣- ស.រ.ហ.អ.ក ២ : ការទូទាត់ដោយផ្អែកលើចំណែកហ៊ុន

៤- ស.រ.ហ.អ.ក ៣ : ការរួមបញ្ចូលអាជីវកម្ម

៥- ស.រ.ហ.អ.ក ៥ : ទ្រព្យសកម្មរយៈពេលវែងទុកសម្រាប់លក់ និងប្រតិបត្តិការមិនបន្ត

ស្តង់ដារគណនេយ្យ

៦- ស.គ.អ.ក ១ : ការបង្ហាញពីរបាយការណ៍ហិរញ្ញវត្ថុ

៧- ស.គ.អ.ក ២ : សន្និធិ

៨- ស.គ.អ.ក ៧ : របាយការណ៍លំហូរសាច់ប្រាក់

៩- ស.គ.អ.ក ៨ : គោលនយោបាយគណនេយ្យ ការផ្លាស់ប្តូរការប៉ាន់ស្មានគណនេយ្យ និងកំហុសឆ្គង

១០- ស.គ.អ.ក ១០ : ព្រឹត្តិការណ៍បន្ទាប់ពីការិយបរិច្ឆេទរាយការណ៍

១១- ស.គ.អ.ក ១១ : កិច្ចសន្យាសាងសង់

១២- ស.គ.អ.ក ១២ : ពន្ធលើប្រាក់ចំណូល

១៣- ស.គ.អ.ក ១៦ : ទ្រព្យ រោងចក្រ និងបរិក្ខា

១៤- ស.គ.អ.ក ១៧ : ភតិសន្យា

១៥- ស.គ.អ.ក ១៨ : ចំណូល

១៦- ស.គ.អ.ក ២១ : ឥទ្ធិពលប្រែប្រួលនៃអត្រាប្តូរប្រាក់រូបិយប័ណ្ណបរទេស

១៧- ស.គ.អ.ក ២៣ : បន្ទុកលើប្រាក់កម្ចី

១៨- ស.គ.អ.ក ២៤ : ការលាតត្រដាងព័ត៌មានពីភាគីពាក់ព័ន្ធនានា

១៩- ស.គ.អ.ក ២៧ : របាយការណ៍ហិរញ្ញវត្ថុរួម និងរបាយការណ៍ហិរញ្ញវត្ថុដាច់ដោយឡែក



Downloaded from http://www.khmerlaws.com

២០- ស.គ.អ.ក ៣៧ : សំវិធានធន បំណុលជាយថាហេតុ និងទ្រព្យសកម្មជាយថាហេតុ

២១- ស.គ.អ.ក ៣៨ : ទ្រព្យសកម្មអរូបី

២២- ស.គ.អ.ក ៤០ : ទ្រព្យវិនិយោគ

២៣- ស.គ.អ.ក ៤១ : កសិកម្ម

២៤- ស.គ.អ.ក ២៨ : ការវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ

២៥- ស.គ.អ.ក ៣១ : ភាគកម្មក្នុងក្រុមហ៊ុនរួមទុន

២៦- ស.គ.អ.ក៣២ : ឧបករណ៍ហិរញ្ញវត្ថុ : ការបង្ហាញ

២៧- ស.គ.អ.ក ៣៣ : ចំណេញក្នុងមួយសន្លឹកហ៊ុន

២៨- ស.គ.អ.ក ៣៤ : ការរាយការណ៍ហិរញ្ញវត្ថុក្នុងចន្លោះពេល

២៩- ស.គ.អ.ក ៣៦ : ការធ្លាក់ចុះនៃតំលៃទ្រព្យសកម្ម



Downloaded from http://www.khmerlaws.com